# នៅចំពោះមុខអង្គជំនុំជម្រះពិសេស
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

**សំណុំរឿងលេខ** : ០០២/១៩-០៩-២០០៧-អវតក/អជសង
**ដាក់ទៅ** : អង្គជំនុំជម្រះពិសេស
**ថ្ងៃដាក់** : ថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤
**ភាគីអ្នកដាក់** : សហព្រះរាជអាជ្ញា
**ភាសាដើម** : អង់គ្លេស

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 02-Oct-2014, 15:58
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** **សាធារណៈ**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង:** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

## សំណើរបស់សហព្រះរាជអាជ្ញា សុំបន្ថែមចំនួនទំព័រដើម្បីឆ្លើយតបទៅនឹង បណ្តឹងជិតចិត្តចៅក្រមរបស់ នួន ជា និងការអនុញ្ញាតដើម្បីឆ្លើយតបតែមួយភាសាជាមុនសិន

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោកNicholas KOUMJIAN

**អ្នកទទួលឯកសារ:**

**អង្គចៅក្រមពិសេស**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ហ្ស៊ុត វុទ្ធី
ចៅក្រម Chang-ho CHUNG
ចៅក្រម ម៉ែន ពេជ្រសាលី

**ចម្លងជូន:**

**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

**ចម្លងជូន:**

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSÉ
លោក Arthur VERCKEN

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ
លោកស្រី Marie GUIRAUD

# សំណើ

១. នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ មេធាវីការពារក្តី នួន ជា ("មេធាវីការពារក្តី") បានដាក់បណ្តឹងជំទាស់ជិតចិត្តរបស់ នួន ជា ប្រឆាំងនឹងចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម JEAN-MARC Lavergne និងចៅក្រម យូ ឧត្តរា ("បណ្តឹង")[1] នៅចំពោះមុខអង្គជំនុំជម្រះពិសេស នៃអង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះពិសេស") ដែលបានចាត់តាំងឡើងដោយគណៈកម្មាធិការរដ្ឋបាលតុលាការ ("គរត")[2] សម្រាប់ជំនុំជម្រះលើបណ្តឹងនេះ ។

២. ដោយបានការអនុញ្ញាតពីអង្គជំនុំជម្រះពិសេស[3] បណ្តឹងនេះមានចំនួន៤៥ទំព័រ ជាភាសាអង់គ្លេស និង៧៤ ទំព័រជាភាសាខ្មែរ។

៣. នេះគឺជាទម្លាប់អនុវត្តដែលបានបង្កើតឡើងរបស់អង្គជំនុំជម្រះសាលាដំបូងនៃ អវតក និងអង្គជំនុំជម្រះពិសេសដែលបានបង្កើតឡើងកាលពីមុនមក ដើម្បីផ្តល់សហព្រះរាជអាជ្ញានូវសិទ្ធិ ក្នុងការឆ្លើយតបទៅនឹងបណ្តឹងសុំប្តឹងជំទាស់ជិតចិត្តចៅក្រម[4]។ ផលប្រយោជន៍របស់សហព្រះរាជអាជ្ញា នៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះ ជាទូទៅ បានបង្ហាញឱ្យឃើញនូវឋានៈរបស់អង្គជំនុំជម្រះពិសេស

---

[1] **E314/6** បណ្តឹងជំទាស់ជិតចិត្តរបស់ នួន ជា ប្រឆាំងនឹងចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម JEAN-MARC Lavergne និងចៅក្រម យូ ឧត្តរា, ២៩ កញ្ញា ២០១៤ ("បណ្តឹង")។

[2] **E314/4** សេចក្តីសម្រេចរបស់គណៈកម្មាធិការរដ្ឋបាលតុលាការទាក់ទងនឹងការចាត់តាំងសមាសភាពចៅក្រមដើម្បីពិនិត្យ និងវិនិច្ឆ័យលើបណ្តឹងជិតចិត្តប្រឆាំងនឹងចៅក្រមអង្គជំនុំជម្រះសាលាដំបូង, ៤ កញ្ញា ២០១៤។

[3] អ៊ីម៉េលពីការិយាល័យអ្នកច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ជូនក្រុងស៊ុលតង់ជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់របស់មេធាវីការពារក្តី នួន ជា "យោង: សេចក្តីជូនដំណឹង និងសំណើទាក់ទងនឹងញត្តិប្តឹងជំទាស់ជិតចិត្តចៅក្រមនៅពេលខាងមុខ", ១១ កញ្ញា ២០១៤។

[4] សូមមេត្តាអាន ឧទា. ដូចជាឯកសារលេខ **E55** ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសុំប្តឹងជំទាស់ជិតចិត្តចៅក្រមរបស់ អៀង ធីរិទ្ធ, អៀង សារី, និង នួន ជា, ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១។ ឯកសារលេខ **E63/2**, ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងប្តឹងជំទាស់ជិតចិត្តលោកចៅក្រម យូ ឧត្តរា ពីក្នុងអង្គជំនុំជម្រះពិសេសរបស់ អៀង ធីរិទ្ធ, ចុះថ្ងៃទី២៤ មីនា ២០១១ ។ ឯកសារលេខ **E137/4** ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹង៖ ១) សំណើជាបន្ទាន់របស់ នួន ជា ប្តឹងជំទាស់ជិតចិត្តលោកស្រីចៅក្រម Cartwright ។ និង២) សំណើរបស់ អៀង សារី សុំឱ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹងការប្រាស្រ័យទាក់ទង *ជាមួយភាគីតែម្ខាង* រវាងសហព្រះរាជអាជ្ញាអន្តរជាតិ, លោកស្រីចៅក្រម Cartwright និងចៅក្រមផ្សេងទៀត, ចុះថ្ងៃទី១ ធ្នូ ២០១១។ ឯកសារលេខ **E171/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងប្តឹងជំទាស់ជិតចិត្តលោកស្រីចៅក្រម Cartwright លើកទីពីររបស់ នួន ជា, ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ ។ ឯកសារលេខ **E191/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងរបស់ អៀង សារី ប្តឹងជំទាស់ជិតចិត្តលោកស្រីចៅក្រម Cartwright អនុលោមតាមវិធាន៣៤ ឬ ជាជម្រើសផ្សេង សំណើសុំការណែនាំ និងការបង្គាប់ឱ្យបញ្ឈប់ធ្វើការប្រាស្រ័យទាក់ទង *ជាមួយតែភាគីម្ខាង* និងសំណើសុំឱ្យបង្ហាញអំពីការប្រាស្រ័យទាក់ទងនានាជាមួយភាគីតែម្ខាង, ចុះថ្ងៃទី១០ ឧសភា ២០១២។ ឯកសារលេខ **E314/3** ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ ខៀវ សំផន សុំឱ្យផ្អាកកិច្ចដំណើរការនីតិវិធី ឬ ប្តឹងជំទាស់ជិតចិត្តចៅក្រម, ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៤។

ថាជាមន្ត្រីតុលាការនៅក្រោមច្បាប់កម្ពុជា[5]។ លើសពីនេះ មិនដូចបណ្តឹងជំទាស់ពីមុនទេ បណ្តឹងជំទាស់នេះផលប៉ះពាល់ដោយផ្ទាល់ និងធ្ងន់ធ្ងរ ចំពោះផលប្រយោជន៍របស់ការិយាល័យសហព្រះរាជអាជ្ញា(OCP)។ អវតក គឺជាស្ថាប័នមួយ ដែលមានអង្គជំនុំជម្រះសាលាដំបូងតែមួយគត់ប៉ុណ្ណោះ។ បើសិនជាបណ្តឹងជំទាស់ត្រូវបានផ្តល់ការអនុញ្ញាតិឲ្យនោះ ចៅក្រមបរទេសអាចចាំបាច់ត្រូវធ្វើការជ្រើសរើស និងតែងតាំងជាថ្មីម្តងទៀតដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលចៅក្រមទាំងនោះមកដល់ប្រទេសកម្ពុជា ហើយអានឯកសារសម្រាប់ត្រៀមចូលរួមនៅក្នុងសវនាការជំនុំជម្រះក្តី ដែលមានប្រតិចារឹកប្រមាណជា២៥០០០ទំព័រ នៅក្នុងសំណុំរឿងរួចជាស្រេចទៅហើយ។ ការណ៍នេះអាចធ្វើឲ្យអូសបន្លាយពេលក្នុងការចាប់ផ្តើម និងក្នុងការបំពេញឲ្យបានរួចរាល់នូវសំនុំរឿងលេខ០០២/០២ យ៉ាងហោចណាស់ក៏ត្រឹមប្រាំមួយខែ ឬទំនងជាលើសពីនេះទៅទៀត។ ដោយសារតែវ័យចាស់ជរារបស់ជនរងគ្រោះ និងរបស់សហជនជាប់ចោទនោះ ការពន្យារពេលបែបនេះ គឺជាការគម្រាមកំហែងចំពោះលទ្ធភាពនៃការធ្វើសវនាការជំនុំជម្រះបានចប់សព្វគ្រប់លើបទចោទប្រកាន់សំខាន់ៗទាំងឡាយ ដែលនៅសល់នៅក្នុងសំណុំរឿងលេខ០០២/០២។

៤. ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងនេះ ត្រូវផុតកំណត់នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤ ដែលមានរយៈពេល១០ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃជូនដំណឹងនៃបណ្តឹងនេះ[6]។ យោងតាមបទដ្ឋាននៃចំនួនទំព័រកំណត់សម្រាប់ចម្លើយតប ដែលមានចែងក្នុងមាត្រា៥.១ នៃសេចក្តីណែនាំអនុវត្តដែលពាក់ព័ន្ធ ចម្លើយតបណាក៏ដោយត្រូវបានកម្រិតត្រឹម១៥ទំព័រ ជាភាសាអង់គ្លេស ឬ៣០ទំព័រ ជាភាសាខ្មែរ។

៥. អនុលោមតាមមាត្រា៥.៤ និង ៧.២ នៃសេចក្តីណែនាំអនុវត្តដែលពាក់ព័ន្ធ សហព្រះរាជអាជ្ញាស្នើឲ្យអង្គជំនុំជម្រះពិសេស អនុញ្ញាតបន្ថែមចំនួន១៥ទំព័រ សម្រាប់ចម្លើយតបរបស់ខ្លួនជាភាសាអង់គ្លេស និងអនុញ្ញាតឲ្យដាក់ជាភាសាអង់គ្លេសជាមុនចំនួន៣០ទំព័រ ដោយច្បាប់បកប្រែជាភាសាខ្មែរ ដែលមានចំនួនមិនលើសពី៦០ទំព័រ នឹងដាក់តាមក្រោយយ៉ាងឆាប់តាមដែលអាចធ្វើទៅបាន។

---

[5] វិធាន១៨(៣)(ក) នៃវិធានផ្ទៃក្នុង។

[6] សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/២០០៧/១/វិសោធនកម្មលើកទី៨, ស្តីពីការដាក់ឯកសារនៅចំពោះមុខ អវតក, ៧ មីនា ២០១២, មាត្រា៨.៣ (“សេចក្តីណែនាំអនុវត្ត”)។

៦. ការស្នើសុំបន្ថែមចំនួនទំព័រកំណត់ និងការអនុញ្ញាតដាក់ឯកសាតែមួយភាសាជាដំបូងសិននេះ គឺត្រូវបានធ្វើយុត្តិកម្មដោយកាលៈទេសៈពិសេសទាំងពីរ ដោយសារតែ៖ (ក) សំណើនេះវែង, និង (ខ) ភាពស្មុគស្មាញខាងអង្គហេតុ អង្គច្បាប់ អំណះអំណាងខាងគោលនយោបាយសាធារណៈអន្តរជាតិ និងខាងធម្មនុញ្ញ ដែលមានភាពជឿនលឿននៅក្នុងនោះ។ ខណៈដែលមេធាវីការពារក្តីត្រូវបានអនុញ្ញាតឱ្យមានការបន្ថែមចំនួនទំព័រកំណត់លើសបីដង នោះសហព្រះរាជអាជ្ញាបានកម្រិតសំណើរបស់ខ្លួនត្រឹមតែ២(ពីរ)ដង នៃចំនួនទំព័រកំណត់ដែលបានអនុញ្ញាត និងពុំមានការស្វែងរកស្នើសុំបន្ថែមពេលវេលានោះឡើយ ជាប្រយោជន៍ដើម្បីឱ្យមានលក្ខណៈខ្លីច្បាស់លាស់ និងដើម្បីប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធីឆាប់រហ័សទាំងនេះ។

៧. ចំពោះហេតុផលទាំងនេះ សហព្រះរាជអាជ្ញាស្នើដោយគោរពដល់អង្គជំនុំជម្រះពិសេស អនុញ្ញាតឱ្យមានការបន្ថែមទំព័រកំណត់ចំនួន១៥(ដប់ប្រាំ)ទំព័រ និងឱ្យសហព្រះរាជអាជ្ញា៣០(សាមសិប) ទំព័រ ដើម្បីដាក់ចម្លើយតបរបស់ខ្លួន តែភាសាអង់គ្លេសមួយជាដំបូងសិន ហើយដាក់ការបកប្រែជាភាសាខ្មែរតាមក្រោយ ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | | [signature] |